**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខៈ ...១៤០ ប្រ.ក...

# ប្រកាស
## ស្ដីពី
## ការគ្រប់គ្រង អាជីវកម្ម ឌីសអុបទីក និងឧបករណ៍ថតចម្លង

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

-បានឃើញអនុក្រឹត្យលេខ ២៨អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-យោងតាមការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅ គ្រប់គ្រងអាជីវកម្មឌីសអុបទីកដែលមិនទាន់ផ្ទុកទិន្នន័យ និងឧបករណ៍ថតចម្លងគ្រប់ប្រភេទ ក្នុងគោលបំណងដើម្បីធានាឲ្យបាននូវកិច្ចការពារផ្នែកកម្មសិទ្ធបញ្ញានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ឌីសអុបទីកដែលមិនទាន់ផ្ទុកទិន្នន័យរួមមាន ៖

១- ស៊ីឌី CD ( Compact Disc )

២- ស៊ីឌី ឌីអេ CD-DA ( Compact Disc Digital Audio )

៣- ស៊ីឌី អាយ CD-I ( Compact Disc-Interactive )

ទូរស័ព្ទ / ទូរសា ៖ 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

៤- ស៊ីឌី ភី CD-P ( Compact Disc- Photo )
៥- ស៊ីឌី រ៉ូម CD-ROM ( Compact Disc Read-Only Memory )
៦- ស៊ីឌី រ៉ាយ CD-R ( Compact Disc Recordable )
៧-ស៊ីឌី រីរ៉ាយ CD-RW ( Compact Disc Re-Writable )
៨- ស៊ីឌី វ៉ូ CD-WO ( Compact Disc Write Once )
៩- ឌីវីឌី DVD (Digital Versatile Disc )
១០- ឌីវីឌី រ៉េម DVD-RAM ( Digital Versatile Disc Random Access Memory )
១១- ឌីវីឌី រ៉ូម DVD-ROM ( Digital Versatile Disc Read-Only Memory )
១២- ឌីវីឌី រ៉ាយ DVD-R ( Digital Versatile Disc Recordable )
១៣- ឌីវីឌី រីរ៉ាយ DVD-RW (Digital Versatile Disc Re-Writable )
១៤- អិលឌី LD ( Laser Disc )
១៥- អិមឌី MD ( Mini Disc )
១៦- វីស៊ីឌី VCD ( Video Compact Disc )
១៧- ស៊ីវីឌី CVD ( China Video Disc )
១៨- អេសវីស៊ីឌី SVCD ( Super Video Compact Disc )
១៩- អេសអេស៊ីឌី SACD ( Super Audio Compact Disc )
២០- អ៊ីវីឌី EVD ( Enhanced Versatile Disc ) និង
២១- វត្ថុធាតុដើមផ្សេងៗ ទៀតនៃឌីសអុបទីក ។

**ប្រការ៣.~**

ឧបករណ៍ថតចម្លងរួមមាន ៖

១-ម៉ាស៊ីនថតចម្លងគ្រប់ប្រភេទ
២-ម៉ាស៊ីនកុំព្យូទ័រ ហាតឌៀ
៣-ឧបករណ៍ ឬម៉ាស៊ីនភ្ជាប់ដើម្បីបង្ហាញនូវ ទិន្នន័យព័ត៌មាន សម្លេង ឬរូបភាព
៤-ម៉ាស៊ីនបោះពុម្ព
៥-ម៉ាស៊ីនស្កេន
៦-ទូរសព្ទដៃគ្រប់ប្រភេទ
៧-យូអេសប៊ី (USB) អឹមភីស្រ៊ី (MP3) អឹមភីហ្វរ(MP4) អឹមភីហ្វាយ(MP5) ឬឧបករណ៍ផ្សេងទៀត ដែលមានសមត្ថភាពអាចផ្ទុកទិន្នន័យព័ត៌មាន សម្លេង ឬរូបភាពបាន និង
៨-គ្រឿងបន្លាស់ សម្រាប់ផលិតឧបករណ៍ថតចម្លង ។

**ប្រការ៤.~**

រាល់ការធ្វើអាជីវកម្មផលិត ការនាំចេញនាំចូល ការលក់ចែកចាយឌីសអុបទីក ការផលិត ការនាំចេញនាំចូល ការបើកកន្លែងថតម្លើង ជួសជុល ជួលនិងលក់ចែកចាយឧបករណ៍ថតចម្លងត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

**ប្រការ៥.~**

សំណុំបែបបទនិងឯកសារចាំបាច់ផ្សេង ៗ ដែលពាក់ព័ន្ធនិងការស្នើសុំធ្វើអាជីវកម្ម ឌីសអុបទីក និង ឧបករណ៍ថតចម្លង ត្រូវកំណត់ដោយនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៦.~**

រាល់ការអនុញ្ញាតធ្វើអាជីវកម្ម ដូចមានចែងក្នុងប្រការ៤ខាងលើ ត្រូវបង់កម្រៃសេវាកម្ម ដែលកំណត់ដោយ ប្រកាសអន្តរក្រសួង រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៧.~**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-គ្រប់សាលារាជធានី ខេត្ត
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ